Minnesota Department of Education

សំណួរ និងចម្លើយអំពី MCA ក្នុងគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ

នៅនិទាយរដូវ 2014

តើ MCAs គឺជាអ្វី?

ការវាយតម្លៃអំពីការយល់ដឹង មីណេសូតា (MCAs) គឺជាតេស្តរបស់រដ្ឋក្នុងមុខវិជ្ជាគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់អប់រំសាលាបឋមសិក្សា និងវិទ្យាល័យសហព័ន្ធ (ESEA)។ តេស្តទាំងនេះត្រូវបានផ្តល់ជាដៀងរាល់ឆ្នាំដើម្បីវាស់ស្ទង់ការអនុវត្តរបស់សិស្សធៀបនឹងបទដ្ឋានសិក្សាមីណេសូតាដែលបំពេញពីអ្វីដែលសិស្សក្នុងថ្នាក់ពិសេសគួរចេះ និងអាចធ្វើបាន។

ហេតុអ្វីបានជាយើងឲ្យតេស្តទាំងនេះដល់សិស្ស?

យើងប្រើ MCAs ដើម្បីស្វែងយល់ថាសាលាបានស្របទៅតាមកម្មវិធី និងបង្រៀនសិស្សនៅក្នុងបទដ្ឋានសិក្សាប្រចាំមីណេសូតានៅក្នុងផ្នែកគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ។ ការវាយតម្លៃគណិតវិទ្យា និង អំណានក៏ត្រូវបានប្រើក្នុងការវាស់ស្ទង់ការទទួលខុសត្រូវរបស់សាលាសហព័ន្ធដែរ។
សាលាប្រើព័ត៌មានដើម្បីកែលម្អការបង្រៀន និងការសិក្សាក្នុងថ្នាក់។ លោកគ្រូអ្នកគ្រូ និងនាយក ស្វែងរកចំណុចដែលសិស្សធ្វើបានល្អ ដូច្នេះពួកគាត់អាចពង្រឹងវិធីសាស្ត្រដែលពួកគាត់បង្រៀនជំនាញទាំងនេះ។ ពួកគាត់ក៏ស្វែងរកចំណុចដែលចាំបាច់ដើម្បីកែលម្អ ដូច្នេះពួកគាត់អាចបង្កើនពេលវេលាបង្រៀន ឬកែប្រែការបង្រៀនរបស់ពួកគាត់។

តើនរណាត្រូវធ្វើតេស្តទាំងនេះ?

រដ្ឋមីណេសូតា និង ESEA តម្រូវឲ្យសិស្សទាំងអស់នៅក្នុងសាលារដ្ឋចូលរួមក្នុងកម្មវិធីវាយតម្លៃទូទាំងប្រទេស។ តេស្តគណិតវិទ្យា និងអំណាននៅក្នុងថ្នាក់ទី 3 ដល់ទី 8 និងវិទ្យាល័យ (សិស្សក្នុងថ្នាក់ទី 10 ប្រឡង MCA អំណាន ហើយសិស្សនៅក្នុងថ្នាក់ទី 11 MCA គណិតវិទ្យា)។ MCA វិទ្យាសាស្ត្របានផ្តល់ឲ្យចំពោះសិស្សនៅក្នុងថ្នាក់ទី 5 ទី 8 និងថ្នាក់វិទ្យាល័យពេលពួកគេជ្រើសយកមុខវិជ្ជាជីវៈវិជ្ជា និង
វិទ្យាសាស្ត្រជីវិត។ ការលើកលែងមួយចំនួន សិស្សសាលារដ្ឋទាំងអស់ក្នុងថ្នាក់ខាងលើប្រឡង MCAs។
សិស្សដែលមានកម្មវិធីអប់រំដោយខ្ជួនឯង (IEP) ឬផែនការ 504 អាចទទួលបានសិទ្ធិគ្រប់គ្រាន់សម្រាប់ការស្នាក់នៅ។ សិស្សមួយចំនួនអាចទទួលបានសិទ្ធិប្រឡង MCA-Modified ការវាយតម្លៃជំនួសដោយផ្អែកលើបទដ្ឋានលទ្ធផលដែលបានកែប្រែក្នុងគណិតវិទ្យា និងអំណាន។ សិស្សផ្សេងទៀតដែលកម្សោយ ខាងខួរក្បាលធ្ងន់ធ្ងអាចទទួលបានសិទ្ធិធ្វើតេស្តមីណេសូតានៅលើជំនាញសិក្សា (MTAS) ការ វាយតម្លៃ ជំនួសដោយផ្អែកលើបទដ្ឋានលទ្ធផលជំនួសផ្នែកគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ។ *មើលលក្ខខណ្ឌតម្រូវដែលទទួលបានសិទ្ធិនៃការវាយតម្លៃជំនួសព័ត៌មានបន្ថែមនៅលើគេហទំព័រក្រសួងអប់រំមីណេសូតា*។ (ចូលទៅកាន់ទំព័រ School Support>Test Adminitration>Minnesota Test។)

តើសិស្សអាចរៀបចំធ្វើតេស្តយ៉ាងដូចម្តេច?

ឯកសារ "ការស្នើឲ្យមានការរៀបចំការធ្វើតេស្តសម្រាប់មាតាបិតា និងគ្រូ" គឺអាចរកបានលើគេហទំព័រក្រសួងអប់រំមីណេសូតា ដោយមានព័ត៌មានបន្ថែមអំពីការរៀបចំខ្លឹមសារ យុទ្ធសាស្ត្រប្រលងទូទៅ និងការប្រើប្រាស់ម៉ាស៊ីនគិតលេខ។ *ពិនិត្យឯកសារការរៀបចំតេស្តលើគេហទំព័រក្រសួងអប់រំមីណេសូតា* ។ (ចូលទៅកាន់ទំព័រ Just for Parent>Testing Information។)

កម្មវិធីជំនួយជួយសិស្សឲ្យសិស្សស្គាល់ពីទម្រង់នៃតេស្ត ហើយផ្តល់ខទាហរណ៍នៃប្រភេទសំណួរដែលមាននៅលើតេស្ត។ អ្នកអាចរកកម្មវិធីជំនួយសម្រាប់ថ្នាក់ និងមុខវិជ្ជានីមួយៗនៅកន្លែងវាយតម្លៃ មីណេសូតា (www.mnstateassessments.org)។ *ពិនិត្យកម្មវិធីជំនួយនៅកន្លែងវាយតម្លៃមីណេសូតា*។

តើធ្វើដូចម្តេចដើម្បីជាប់តេស្ត?

សិស្សដែលធ្លាក់តេស្តអំណាន និងគណិតវិទ្យាដែលមាននៅក្នុងថ្នាក់ទី 3 ដល់ទី 8 ឬតេស្តវិទ្យាសាស្ត្រដែលមាននៅថ្នាក់ទី 5 ទី 8 និងវិទ្យាល័យ។ សិស្សម្នាក់ៗទទួលបានពិន្ទុដែលធ្លាក់មួយក្នុងចំណោមកម្រិតលទ្ធផលបួន — មិនបំពេញតាមបទដ្ឋាន បំពេញតាមបទដ្ឋានបានមួយផ្នែក បំពេញតាមបទដ្ឋាន និងលើសពីបទដ្ឋាន។

MCA អំណានថ្នាក់ទី 10 និង MCA គណិតវិទ្យាថ្នាក់ទី 11 អាចត្រូវបានប្រើដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សា។ ប្រសិនបើសិស្សបានបំពេញ ឬលើសពីបទដ្ឋាន សិស្សទាំងនោះបានបំពេញលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សារបស់ពួកគេសម្រាប់មុខវិជ្ជានោះ។ [ពិនិត្យលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់ការសិក្សាព័ត៌មានសង្ខេបមាតាបិតាលើផបសាយក្រសួងអប់រំមីណេសូតាសម្រាប់ព័ត៌មានបន្ថែមស្តីពីលក្ខខណ្ឌតម្រូវនៃការវាយតម្លៃបញ្ចប់កាសិក្សា](#)។ (ចូលទៅកាន់ទំព័រ Just for Parents > Testing Information។)

តើតេស្តត្រូវបានគ្រប់គ្រងអ្វីខ្លះ?

ចំណាត់ថ្នាក់ទាំងអស់នៃ MCA ត្រូវបានគ្រប់គ្រងតាមបណ្តាញអ៊ីនធឺណិតប៉ុណ្ណោះ។ ចំណាត់ថ្នាក់ MCA ស្តីពីអំណាននិងគណិតវិទ្យាទាំងអស់ត្រូវបានគ្រប់គ្រងតាមបណ្តាញអ៊ីនធឺណិត ឬលើក្រដាសដូចបានកំណត់ដោយសាលានីមួយៗ។

MCAs គណិតវិទ្យាថ្នាក់ទី 3-8 នៅតាមបណ្តាញអ៊ីនធឺណិតមានន័យថាគ្រប់ពេលដែលសិស្សឆ្លើយសំណួរចម្លើយរបស់គាត់ឬនាងជួយកំណត់សំណួរបន្ទាប់ដែលសិស្សនឹងត្រូវឆ្លើយ។

តើជំនាញអ្វីដែលត្រូវបានវាយតម្លៃដោយ MCA?

MCAs វាស់ស្ទង់ការអនុវត្តរបស់សិស្សចំពោះបទដ្ឋានសិក្សាមីណេសូតា។ [ពិនិត្យបទដ្ឋានសិក្សាប្រចាំ មីណេសូតានៅលើគេហទំព័រក្រសួងអប់រំមីណេសូតា](#)។ (ចូលទៅកាន់ទំព័រ Educator Excellence > Standards, Curriculum and Instruction > K-12 Academic Standards។)

- MCA អំណានត្រូវស្របទៅតាមបទដ្ឋានសិក្សាឆ្នាំ 2010 ។
- MCA គណិតវិទ្យាត្រូវស្របទៅតាមបទដ្ឋានសិក្សាឆ្នាំ 2007 ។
- MCA វិទ្យាសាស្ត្រត្រូវបានដាក់បញ្ចូលទៅក្នុងបទដ្ឋានការសិក្សាឆ្នាំ 2009 ។

តើខ្ញុំអាចមើលលទ្ធផល MCA សម្រាប់កូន សាលា និងមណ្ឌលរបស់ខ្ញុំដោយរបៀបណា?

មណ្ឌលសិក្សាធិការនឹងទទួលរបាយការណ៍សិស្សម្នាក់ៗសម្រាប់កុមារនីមួយៗដែលទទួលបាន MCA ហើយនឹងផ្តល់ព័ត៌មាននេះទៅឲ្យមាតាបិតានិងអាណាព្យាបាល។ របាយការណ៍នេះបង្ហាញពីពិន្ទុកូនរបស់អ្នកក្នុងមុខវិជ្ជានីមួយៗក៏ដូចជាសម្រាប់ជំនាញជាក់លាក់ក្នុងមុខវិជ្ជានីមួយៗ។ វាក៏មានព័ត៌មានអំពីកម្រិតលទ្ធផល ការប្រៀបធៀបទៅនឹងក្រុមផ្សេងៗ និងការប្រៀបធៀបទៅនឹងការអនុវត្តរបស់សិស្សក្នុងឆ្នាំកន្លងទៅនៅពេលដែលអាចអនុវត្តបាន។

លទ្ធផលសាលា និងមណ្ឌលមាននៅក្នុងទិន្នន័យសម្រាប់មាតាបិតា និងផ្នែកអ្នកអប់រំនៃមជ្ឈមណ្ឌលទិន្នន័យនៅលើគេហទំព័រក្រសួងអប់រំមីណេសូតា។ [ចូលទៅកាន់ទិន្នន័យសម្រាប់មាតាបិតានិងផ្នែកអ្នកអប់រំនៃគេហទំព័រក្រសួងអប់រំមីណេសូតា](#)។ (ចូលទីកាន់ទំព័រ Data Center > Data for Parents and Educators។)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ការធ្វើតេស្តទូទាំងប្រទេស

mde.testing@state.mn.us

ក្រសួងអប់រំមីណេសូតា

1500 Highway 36 West
Roseville, MN 55113-4266
http://education.state.mn.us

ខែសីហាឆ្នាំ 2013